ថ្ងៃទី ១៨ មករា ២០០៦

កម្រងអត្ថបទមួយចំនួនទំ

ជីវប្រវត្តិពិតរបស់ Monique Izzi

(តាមការរៀបរាប់របស់លោកយាយម្នាក់ដែលជាសិស្សរួមថ្នាក់ជាមួយសីហនុ)

លោកយាយដែលយើងបានសន្ទត់ឈ្មោះថា “មែន-ពិត” បច្ចុប្បន្នមានចំណាស់ប្រមាណប៉ែតសិបឆ្នាំប្លាយហើយ ។ លោកយាយបានកើតនៅក្នុងត្រកូលអភិជនមួយ ដែលធ្លាប់ចូលប្រលូកយ៉ាងសកម្មជាមួយក្រុមពួកអភិជន ពួកអាម៉ឺអាថោង និងពួកចៃវាំងជាដើម ។ លោកយាយធ្លាប់រៀននៅសាលាជាមួយសីហនុ ឬ អាធុល, ធ្លាប់លេងសើចជេរស្តីជាមួយ អាធុលតាំងពីកុមារភាពដូចគ្នា ដូច្នេះហើយបានជា លោកយាយបានដឹងរឿងរ៉ាវជាច្រើន ដែលកើតនៅក្នុង និងក្រៅបរិវេណវាំង ។ លោកយាយថា សីហនុឬ អាធុលជាមនុស្សរបិលរប៉ូចខិលខូចនឹងស្រីៗណាស់ អាធុលតែងទៅញ៉ែប៉ប្រែជាមួយកូនអស់លោកដែលជាមិត្តភក្តស្រីៗ ធ្វើឱ្យគេខឹងសម្បារជេរប្រទិចអាធុលស្ទើររាល់ថ្ងៃ ។ ចរិតអន់ថយថោកទាបនេះក៏ត្រូវពួកយួន និងបារាំងសំលាងមាត់កត់សំគាល់ទុកដែរ ។

ខាងក្រោមនេះគឺជា ប្រវត្តិពិតរបស់ Monique Izzi តាមការរាយរាប់របស់លោកយាយ មែន-ពិត ។

តាមការរ៉ាយរ៉ាប់របស់លោកយាយ មែន-ពិត Monique Izzi គ្មានឈាមខ្មែរមួយតំណក់នៅក្នុងខ្លួនសោះឡើយ ។ ម្តាយបង្កើតរបស់ Monique Izzi ត្រូវជាប្រពន្ធដើមរបស់លោក Françoise Izzi ។ ស្ត្រីនេះជាសាសន៍យួនវៀសុទ្ធសាធ ។ លោក Françoise Izzi បានជួបស្រីយួនវៀនេះនៅពេលដែលលោក បំពេញកិច្ចការនៅស្រុកយួន (មុននឹងផ្លាស់មកស្រុកខ្មែរ) ។ ចំណងដៃនៃការរួមសង្វាសនៃជនទាំងពីរក៏បានបង្កើតចេញកូនស្រីម្នាក់ ដែលមានឈ្មោះថា Monique Izzi ។ ជាអកុសលនៅពេលដែល Monique Izzi កើតមិនបានប៉ុន្មានថ្ងៃផង ស្រីយួនជាម្តាយនោះក៏ទាស់សៃស្លាប់បាត់ទៅ ។ ពេលនោះលោក Françoise Izzi ក៏បានសុំលោកស្រីប៉ុម-ពាង ដែលត្រូវជាលេខាផ្ទាល់របស់ខ្លួន ធ្វើជាមេដោះឱ្យ Monique Izzi ព្រោះកាលណោះ លោកស្រីប៉ុម-ពាង ក៏កំពុងមានកូនខ្ចីមួយដែរ ។ ក្រោយមកលោក Françoise Izzi និង ប៉ុម-ពាង ក៏បានសាហាយស្មន់គ្នា ហើយក៏យកគ្នាជាប្តីប្រពន្ធទៅ ។ ពួកចៃវាំងក្តី ពួកអ្នកសរសេរប្រវត្តិសាស្ត្រខ្មែរក្តី មិនដែលហ៊ានបើកកកាយរឿងនេះទេ ឯជនណាដែលមានបំណងប្រឆាំងតវ៉ាសុទ្ធតែត្រូវសីហនុយក ទៅបាញ់ចោលទាំងកណ្តាលថ្ងៃត្រង់ដោយគ្មានរកខុសត្រូវអ្វីទាំងអស់ ។

## ទស្សនៈការី

ជាច្រើនលើកច្រើនគ្រាហើយដែលសីហនុ រសាប់រសល់ឈរជើងមិនហ្នឹង ចេញមុខសរសេរការពារ និងលើក តម្កើង Monique Izzi ។ មិនតែប៉ុណ្ណោះសីហនុបានទាំងតែងបទចំរៀងរាប់មិនអស់សសើរតម្កើង Monique Izzi ផង ។ គួរឱ្យខ្ពើមឆ្អើមជាងនេះទៅទៀត គឺសីហនុក៏បានតែងបទចំរៀងឱ្យប្រជាជនខ្មែរដែលជាជនរងគ្រោះដោយស្ត្រីនេះសសើរតម្កើងស្រីនេះទៀតផង គួរឱ្យអនិចារដល់រាស្ត្រខ្មែរខ្លាំងណាស់ ។ នេះមិនខុសពីយួនដែលបង្កើតខ្មែរក្រហមមួយក្រុម យកទៅលាងខួរក្បាល ពង្វក់ស្មារតីឱ្យសម្លាប់បំបាត់ពូជសាសន៍ខ្មែរ ហើយវាធ្វើជានាំខ្មែរក្រហមមួយក្រុមទៀតមករំដោះខ្មែរ ដើម្បីឱ្យខ្មែរដឹងគុណវា ចង់វាធ្វើអ្វីក៏ធ្វើទៅ ព្រោះវាជាអ្នកមានគុណ ។ តើជនដែលអាច

ប្រព្រឹត្តិអំពើ ដ៏គំរកថោកទាប អមនុស្សធម៌ អសីលធម៌នេះ ជាមនុស្សបែបណា ? បើខ្លួនចង់ធ្វើអ្វីមួយស្រីនេះក៏ធ្វើទៅជា ចាំបាច់ឱ្យប្រជាជនខ្មែរ ដែលជាជនរងគ្រោះដោយសារស្ត្រីនេះ សសើរតម្កើងពេជឃាតខ្លួនទៅវិញ !?

យាយប៉ុម-ពាងក្តី Monique Izziក្តី សុទ្ធតែជាប្រភេទមនុស្សនិរទេសខ្ចាត់ព្រាត់គ្មានពង្សសាវតា គ្មានប្រវត្តិពិតប្រាកដទេ ។ ដោយយោងទៅតាមសកម្មភាពពួកវា ពួកជនទាំងនេះត្រូវគេយកមកផ្តុកចោលនៅស្រុកខ្មែរដើម្បីបុព្វហេតុនយោបាយ មិនខុសពីបងប្អូនត្រកូល “ជួន” មាន ជួន-មុំ, ជួន-ជុំ, ជួន-ជឿន, ជួន-ប្រសិទ្ធ ដែលសុទ្ធសឹងជាក្បាលមាស៊ីននៃរបបវាលពិឃាតខ្មែរក្រហម/ខ្មែរវៀតមិញ គឺពួកនេះហើយដែលមានទំនាក់ទំនងផ្ទាល់ជាមួយយួន និងជាមាស៊ីនបញ្ជាលើក្បាលពួកខ្មែរក្រហម ។ ក្នុងសៀវភៅ “Sihanouk, fin illusion” របស់លោក André Tong លោកបានសរសេរថា យាយ ប៉ុម-ពាង ជាស្រីចិនកាត់យួន (sino-yuon) មិនខុសពីពួកអៀងសារី ខៀវសំផន ..។ល។ ប៉ុន្មានទេ ។ នៅក្នុងសៀវភៅ “Cambodge, Mémoires d’un coup d’Etat” របស់លោក Nouth Chhoeum លោកបានសរសេរថា អៀង-សារី គឺជាភ្នាក់ងារសំងាត់របស់យួនដែលយួនបញ្ជូនមកអូសទាញក្បាល ប៉ុល-ពត និងឥស្សរជនខ្មែរដទៃទៀត ឱ្យទៅបំរើយួន ។ ដោយយោងលើឯកសារខ្លះៗស្តីពី អៀង-សារីៗ មិនមែនគ្រាន់តែជាភ្នាក់ងារសំងាត់របស់យួនប៉ុណ្ណោះទេ តែក៏ជាភ្នាក់ងាររបស់ចិនដែរ ។ ឯពួកមេខ្មែរក្រហម/ខ្មែរវៀតមិញ ត្រកូល “ជួន” ក៏សុទ្ធតែមានដើមកំណើតជាយួនដែរ ។ លោក André Tong បានសរសេរថា ឪពុកពួកមេខ្មែរក្រហមត្រកូល “ជួន” គឺជាកូនយួនដែលត្រូវគេយកទៅឱ្យរស់នៅជាមួយវាំងជួន ។ នៅក្នុងទស្សនាវដ្តី “ស្វែងរកការពិត” នៃមជ្ឈមណ្ឌលឯកសារកម្ពុជា (Dccam) លោក ជួន-ប្រសិទ្ធ ក៏បានសារភាពថា ជីតារបស់លោក “ជួន” មានដើមកំណើតជាយួន និងជាអ្នកតស៊ូ(យួន) ។ រឿងបែបនេះមិនមែនជាករណីពិសេសគួរឱ្យភ្ញាក់ផ្អើលអ្វីទេ ការពិតនៅក្នុងក្រអៅបេះដូងនៃសង្គមខ្មែរ មានមនុស្សប្រភេទត្រកូលយួន “ជួន” នេះច្រើនណាស់ ដោយខ្លះជាកាកសំណល់ពីជំនាន់ជយ័ជេដ្ឋាទី២រហូតដល់ជំនាន់ស្តេចអង្គម៉ី និងមួយចំនួនធំទៀត ត្រូវបារាំងដឹកចូលមកស្រុកខ្មែរឱ្យត្រួតលើខ្មែរ ដូច្នេះហើយបានជាពួកយួនដែលរស់នៅស្រុកខ្មែរបានដឹងរឿងរ៉ាវក្រលុកក្រល្បៀតពីខ្មែរច្រើនណាស់ ព្រោះពួកវាភាគច្រើនបំរើការខាងរដ្ឋបាល និងមួយចំនួនទៀតជាអ្នកបំរើការជាមន្ត្រីស្តីទីក្នុងបរិវេណវាំង កូនចៅពួកវាសុទ្ធតែបានរៀនសូត្រចេះដឹងជ្រៅជ្រះ ដូច្នេះវាក្តាប់លើខ្មែរដឹកនាំនយាបាយបំផ្លិចបំផ្លាញខ្មែរពីមួយជំនាន់ទៅមួយជំនាន់ ។

ប្រវត្តិ Monique Izzi ដែលសីហនុតាក់តែងឡើងនោះ គឺជាជារឿងឆ្នៃប្រឌិតបន្ថែម ព្រោះសីហនុចង់លើកស្រីម្នាក់នេះដាក់ខ្ពស់លើសអង្គរ (ឆាយាលើអង្គរ) លើក្បាលខ្មែរទាំងអស់ ទោះជាស្រីនេះមានបាតដៃប្រលាក់ឈាមខ្មែរស្លូតត្រង់រាប់លាននាក់ក៏ដោយ ព្រោះស្រីនេះហើយដែលអាចអូសក្បាលសីហនុ អូសប្រទេសខ្មែរឱ្យធ្លាក់នរកយួនរហូតដល់បច្ចុប្បន្ន ។

ការអះអាងថា Monique Izzi និង យាយ ប៉ុម-ពាង ជាខ្មែរ ឬ ជាយួនមិនមែនជាមូលដ្ឋានសំខាន់សម្រាប់យកមកធ្វើការវិនិច្ឆយ័ ឬពិចារណានោះទេ គឺសកម្មភាពនៃជនទាំងនេះទេដែលជាកត្តាកំណត់ ។ ឧបមាថា Monique Izzi និង យាយ ប៉ុម-ពាង មានឈាមជរ័ជាខ្មែរដូចសីហនុសរសេរអះអាងមែន សូមក្រឡេកមើលជំហរ និងសកម្មភាពរបស់មនុស្សអស់នេះកន្លងមកមើល តើមនុស្សអស់នេះបំរើនរណា ? បំរើឱ្យសាសន៍ណា ? មួយជីវិតរបស់ Monique Izzi និង យាយ ប៉ុម-ពាង គឺសម្រាប់តែបំរើនយោបាយវាតទីនិយមរបស់យួន របស់ Uncle Ho Chi Minh របស់ Monique Izzi និង យាយ ប៉ុម-ពាង តែប៉ុណ្ណោះ ។ មានប្រភពខ្មែរខ្លះក៏បានឱ្យដឹងថា យាយប៉ុម-

ពាង ធ្លប់មានទំនាក់ទំនងយ៉ាងជិតស្និតណាស់ជាមួយ Ho Chi Minh និង ជាមួយពួកក្រុមភ្នាក់ងារសំងាត់យួនដែលមកបង្កប់ខ្លួននៅលើទឹកដីខ្មែរនៅម្តុំខេត្តបាត់ដំបង និងទីរួមខេត្តខ្មែរដទៃទៀត ដើម្បីលួចធ្វើសកម្មភាពនយោបាយរបស់ពួកវា តាំងតែពីជំនាន់អាណានិគមនិយមបារាំងមកម្លេះ ។ ពួកយួនទាំងនេះហើយដែលជាមេអាថិជួយជ្រោមជ្រែងខ្មែរឱ្យបង្កើតចលនាឥស្សរះក្រោមខ្សែរញាក់របស់យួន ។ ពេលដែលបារាំងចាកចេញពីឥណ្ឌូចិន, ចលនានេះបានរំលាយខ្លួនជាចលនាខ្មែររៀតមិញ ហើយក្រោយមកក៏ត្រូវសីហនុដាក់ឈ្មោះថា ចលនាខ្មែរក្រហម ។

បើគេពិនិត្យនូវគ្រប់សកម្មភាពរបស់ Monique Izzi និង យាយ ប៉ុម-ពាង នោះគេមានអារម្មណ៍ថា Monique Izzi និង យាយ ប៉ុម-ពាង ត្រូវគេបញ្ជូនមករស់នៅក្បែរសីហនុដើម្បីបេសកកម្មចំបងពីរគឺ យកការពីខ្មែរឱ្យយួន និង អូសក្បាល សីហនុឱ្យងប់ងល់បំរើនយោបាយចិន-យួន រហូតអស់ដី អស់ប្រទេស អស់ជីវិតខ្មែររាប់លាននាក់ ។ នៅពេលដែលពួកយួនយៀកកុង ជិតងាប់តែហោងដាច់ពូជដោយការទម្លាក់ Bombs B52 របស់អាមេរិកកាំង ទៅហើយ វត្តមានរបស់ Monique Izzi ក្បែរសីហនុ បានបើកផ្លូវឱ្យយួនបានបោះទីតាំងនៅលើដីខ្មែរ និង យកដីខ្មែរជាទីតាំងលាក់បំពួនកងទព័យួន សម្រាប់វាយប្រហារកងទព័អាមេរិកកាំង ។ មិនតែប៉ុណ្ណោះ Monique Izzi និង យាយ ប៉ុម-ពាង បានប្រើប្រាស់ឋានៈខ្លួន ជាមហេសី និង ជាម៉ែក្មេករបស់ស្តេច បញ្ជាកម្លាំងកងខេមរភូមិន្ទ ដែលដឹកនាំដោយលោកលន់-ណុន ឱ្យដឹកជញ្ជូនស្បៀងអាហារ និង សម្ភារៈសឹកពីកំពុងផែកំពង់សោមទៅផ្គត់ផ្គង់កងទព័យួន ឱ្យវាយប្រហារអាមេរិកកាំង និង កាប់សម្លាប់ប្រជាជនខ្មែរ ។ ការដឹកស្បៀងអាហារ និង សម្ភារៈសឹកយ៉ាងគគ្រឹកគគ្រេងទៅផ្គត់ផ្គង់យួននេះ ត្រូវជនទុច្ចរិតទាំងនេះបកស្រាយថា ជាការរកស៊ីរត់ពន្ធដារជាមួយយួន តែការពិត Monique Izzi យាយប៉ុម-ពាង និង សីហនុ គ្មានបានកម្រៃចំណេញអ្វីពីការស៊ីរត់ពន្ធដារជាមួយយួននោះទេ ផ្ទុយទៅវិញវារិតតែធ្វើឱ្យសេដ្ឋកិច្ចខ្មែរដែលកំពុងដុនដាបស្រាប់ រិតតែធ្លាក់ស្រុតកែមិនឡើងដូចមនុស្សឈឺដេកស្តូកស្តឹងលើគ្រែរេះកាត់ ហើយត្រូវគេកាត់សសៃបង្ហូរយកឈាមទៅចិញ្ចឹមបិសាចដាច់អាហារ ព្រោះស្បៀងអាហារដ៏តិចតួចស្តួចស្តើងដែលទុកសម្រាប់ចិញ្ចឹមខ្មែរនាពេលកើតកលិយុគ ត្រូវ Monique Izzi យាយប៉ុម-ពាង និង សីហនុ យកទៅចិញ្ចឹមញាត្តិយួនរបស់ពួកវាអស់ទៅហើយ ។ ជាទិសដៅសំខាន់របស់ពួកវាដែរ គឺ ចិញ្ចឹមយួន, បំប៉នយួនឱ្យមានកម្លាំងដើម្បីឱ្យយួនមានកម្លាំងវាយប្រហារអាមេរិកកាំង និងកាប់សម្លាប់ប្រជាជនខ្មែរ តែប៉ុណ្ណោះ ។

យោងតាមលោក André Tong តាមរយៈសៀវភៅ “ Sihanouk, fin illusion ” និងលោក Pierre Marc , តាមរយៈសៀវភៅ « Cambodge du Silence », នាដើមទសវត្សទី៧0 នៅពេលដែលសីហនុ ប្រុងរត់ចោលស្រុកខ្មែរទៅចូលរួមជាមួយចិន-យួន និងខ្មែរក្រហមឯប៉េកាំង លោកលន់-ណុលបានធ្វើដំណើរដោយផ្ទាល់មកស្រុកបារាំងតាមអង្វរសីហនុឱ្យត្រលប់ទៅស្រុកខ្មែរវិញ តែសីហនុចចេសមិនព្រមត្រលប់ទៅវិញ ធ្វើឱ្យលោកលន់-ណុលអស់សង្ឃឹម និងខកចិត្តជាខ្លាំង ។ មិនអស់ចិត្ត ពេលត្រលប់មកដល់ស្រុកខ្មែរវិញ លោកលន់-ណុលបានកោះប្រជុំបណ្តាឥស្សរខ្មែរជនជាន់ខ្ពស់ហើយបានសម្រេចចិត្តថា នឹងបញ្ជូនឥស្សរជនខ្មែរពីររូប គឺ Prince Kantul និង Mr Yim Sambou ឱ្យមកអង្វរចចារ និងអញ្ជើញសីហនុឱ្យត្រលប់មកស្រុកខ្មែរវិញ តែដោយសីហនុនៅតែចចេសយ៉ាងដាច់ខាតមិនព្រមចចារឬទទួលឥស្សរជនខ្មែរទាំងពីរ ដោយចិត្តមានៈចង់ទៅចូលរួមធ្វើកុម្មុនិស្តជាមួយ ចិន-យួននិងខ្មែរក្រហមដដែល ដូច្នេះគម្រោងការណ៍នេះក៏ត្រូវរអាកខានវិញ ។

មុនថ្ងៃដែលរដ្ឋសភាខ្មែរសម្រេចចិត្តបោះឆ្នោតទម្លាក់សីហនុ ព្រោះសីហនុរត់ចោលតំណែងរបស់ខ្លួន លោកស្រី Ung Bun Hor បានឈ្លួតទៅជួប សីហនុ និង មូនិក ឯក្រុងប៉ារីសដើម្បីលាពួកគេទាំងពីរ ។ នៅទីនោះ លោកស្រីជាសាក្សីចំពោះព្រឹត្តិការណ៍ដ៏ប្រកបដោយគ្រោះថ្នាក់នៃ ប្រទេសខ្មែរ ។ លោកស្រីបានមានប្រសាសន៍ថា នាថ្ងៃនោះពេញមួយថ្ងៃ ពួកឥស្សរជនខ្មែរទាំងឡាយបានទូរស័ព្ទមក អង្វករសីហនុឱ្យត្រលប់មកស្រុកខ្មែរវិញ ។ ដោយគេអង្វករខ្លាំងពេក នៅទីបំផុត សីហនុក៏សម្រេចចិត្តថានឹង ត្រលប់មកស្រុកខ្មែរវិញនៅព្រឹកស្អែក សីហនុបានទាំងឱ្យគេកក់យន្តហោះសម្រាប់ដំណើរវិលត្រលប់របស់គាត់ ។ ព្រឹកឡើង លោកស្រី Ung Bun Hor បានត្រលប់ទៅជួប សីហនុ និង មូនិក ម្តងទៀត ពេលនោះគេបានប្រាប់ លោកស្រីថា សីហនុផ្លាស់ប្តូរចិត្តវិញហើយ ដោយសារតែការណែនាំរបស់ មូនិច និងយាយ ប៉ុម-ពាង ។ ព្រឹត្តិការណ៍ នេះបញ្ជាក់ប្រាប់យើងថា កូនសោរនៃរបបវាលពិឃាត គឺស្ថិតនៅក្នុងដៃ មូនិច និងយាយ ប៉ុម-ពាង ឯណោះ ។ បើគ្មានសីហនុ និងបរិវារទេ ចិន-យួន និងកូនចៅខ្មែរក្រហមរបស់ពួកវា មិនអាចធ្វើអ្វីប្រជាជនខ្មែរបានឡើយ ។

ដូច្នេះបើយោងទៅតាមសកម្មភាពរបស់ Monique Izzi និង យាយប៉ុម-ពាង ព្រមទាំងបក្សពួកមនុស្សនេះ គេអាចវិនិច្ឆ័យបានថា **វាជាសកម្មភាពយួនសុទ្ធសាធ** ការបកស្រាយដទៃទៀតវាគ្រាន់តែជាលេសសំរាប់លាក់បាំងឧក្រិដកម្មរបស់ពួកនេះតែប៉ុណ្ណោះ ។ ម្ទេសទុំ